00643916

E43

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក-អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: **សាធារណៈ / Public**

ស្ថានភាពចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

## អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (អាជ្ញាយុកាលលើអំពើចំពារចំពានធ្ងន់ធ្ងរ)

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវី:** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម **និល ណុន** ជាប្រធាន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម Silvia CARTWRIGHT | លោក Andrew CAYLEY |
| | ចៅក្រម **យ៉ា សុខន** | |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រម **ធូ មណី** | |
| | ចៅក្រមបំរុង **យូរ ឧត្តរា** | |
| | ចៅក្រមបំរុង Claudia FENZ | |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 14 / 02 / 2011
ម៉ោង (Time/Heure): 11:08
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") លោក **អៀង សារី** តាមរយៈសហមេធាវីរបស់ខ្លួន ("មេធាវីការពារក្ដី") សូមដាក់អញ្ញត្រកម្មនេះទាក់ទិននឹងយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការយកបញ្ញត្តិស្ដីពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាក្រុងហ្សឺណែវមកអនុវត្ត ("អំពើបំពារបំពានធ្ងន់ធ្ងរ") ។ សំណើនេះមានភាពចាំបាច់ ដោយហេតុថាអាជ្ញាយុកាលដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បានហាមឃាត់ការយកមាត្រា ៦ នៃច្បាប់បង្កើត អ.វ.ត.ក មកអនុវត្ត (បទល្មើសរំលោភបំពានធ្ងន់ធ្ងរ)។ អញ្ញត្រកម្មនេះត្រូវបានធ្វើឡើងក្រោមដោយយោលទៅលើលក្ខខណ្ឌដែលមានលក្ខណៈអរូបិយ ព្រោះតែមិនបានទទួលអត្ថប្រយោជន៍ពីសំអាងហេតុនៃសាលដីការបស់អង្គបុរេជំនុំជម្រះ ទៅលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[1]។

## I. **ឧទ្ទិករណ៍**

១. ការយកបញ្ញត្តិស្ដីពីអំពើបំពារបំពានធ្ងន់ធ្ងរមកអនុវត្តនៅ អ.វ.ត.ក គឺអាស្រ័យទៅលើអាជ្ញាយុកាលនៃបទល្មើសដែលបានផុតកំណត់ទៅហើយ។ ដូច្នេះ ការផុតអាជ្ញាយុកាលនេះរារាំង អ.វ.ត.ក មិនឱ្យមានយុត្តាធិការក្នុងការយកបញ្ញត្តិស្ដីពីអំពើបំពារបំពានធ្ងន់ធ្ងរមកអនុវត្ត។ ត្រង់ផ្នែកពាក់ព័ន្ធ មាត្រា ៤ នៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក ចែងថា "អំពើប្រល័យពូជសាសន៍, <u>ដែលគ្មានអាជ្ញាយុកាល</u>...."[2]។ ត្រង់ផ្នែកពាក់ព័ន្ធ មាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក ចែងថា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ <u>ដែលគ្មានអាជ្ញាយុកាល....</u>"[3]។ ប៉ុន្តែ ពាក់ព័ន្ធនឹងអំពើបំពារបំពានធ្ងន់ធ្ងរ មាត្រា ៦ នៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក ពុំមានបញ្ជាក់ថាអំពើបំពារបំពានធ្ងន់ធ្ងរគ្មានអាជ្ញាយុកាលនៃបទល្មើសឡើយ។ ដូច្នេះ គេត្រូវចាត់ទុកថាអំពើបំពារបំពានធ្ងន់ធ្ងរគឺជាបទល្មើសដែលមានអាជ្ញាយុកាល។

---

[1] មួយផ្នែកនៃសាលដីកាគឺជាសំអាងរបស់វា។ ការមិនមានសំអាងហេតុបែបនេះ មេធាវីការពារក្ដី បានបំពេញកាតព្វកិច្ចមួយផ្នែករបស់ខ្លួនក្នុងការធ្វើអញ្ញត្រកម្មនេះ តាមរយៈប្រាជ្ញាញាណ ដោយព្យាយាមទស្សទាយនូវសំអាងហេតុរបស់ អង្គបុរេជំនុំជម្រះ ក្នុងការបដិសេធទឡ្ហីករណ៍របស់មេធាវីការពារក្ដី ដែលបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ។ *រឿងក្ដី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ ៧៥) បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះ ស្រាយ ចុះថ្ងៃទី ២៥ តុលា ២០១០ ឯកសារលេខ D427/1/6, ERN: 00617486-00617631។

[2] គូសបញ្ជាក់បន្ថែម។

[3] គូសបញ្ជាក់បន្ថែម។

២. ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ កំណត់អាជ្ញាយុកាលចំនួន ១០ ឆ្នាំ សម្រាប់ទោសឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅកម្ពុជា[4]។ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បានចាត់ទុកទោសឧក្រិដ្ឋជាទោសមួយដែលត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារជាអប្បបរមាចំនួន ៥ ឆ្នាំ[5]។ បទឧក្រិដ្ឋបំពារបំពានធ្ងន់ធ្ងរត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារជាអប្បបរមាចំនួន ៥ ឆ្នាំ នៅ អ.វ.ត.ក[6]។ ដូច្នេះ គេត្រូវចាត់ទុកថាអំពើបំពារបំពានធ្ងន់ធ្ងរជាទោសឧក្រិដ្ឋមួយ។ ដូច្នេះ អំពើបំពារបំពានធ្ងន់ធ្ងរមានអាជ្ញាយុកាលនៃបទល្មើសចំនួន ១០ឆ្នាំ។ រយៈពេល ១០ ឆ្នាំនេះ បានកន្លងហួសរួចទៅហើយនៅឆ្នាំ ១៩៨៩ សម្រាប់បទល្មើសឧក្រិដ្ឋនានាដែលចោទថាបានប្រព្រឹត្តនៅក្នុងឆ្នាំ ១៩៧៩។

៣. មាត្រា ៣ ថ្មីនៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋជាតិ ចែងត្រង់ផ្នែកពាក់ព័ន្ធថា "អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ត្រូវបានពន្យារពេលបន្ថែម ៣០ ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ...."។ បទឧក្រិដ្ឋ "ទាំងឡាយខាងលើ" ក្នុងមាត្រា ៣ ថ្មី គឺសុទ្ធសឹងជាបទឧក្រិដ្ឋជាតិទាំងអស់។ ដូច្នេះ ការពន្យារថិរវេលាលើអាជ្ញាយុកាលនេះ បើទោះជាយកមកអនុវត្ត គឺពិត ជាមិនអាចយកមកអនុវត្តចំពោះអំពើបំពារបំពានធ្ងន់ធ្ងរឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង មិនមានយុត្តាធិការយកមកប្រើប្រាស់នូវមាត្រា ៦ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ប្រឆាំងនឹងលោក អៀង សារី បានឡើយ ។

---

[4] ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦, ត្រង់ផ្នែកពាក់ព័ន្ធ មាត្រា ១០៩ ចែងថា៖ "អ្នកណាប្រព្រឹត្តឧក្រិដ្ឋកម្មកន្លងលើសពី ១០ ឆ្នាំ... អ្នកនោះបានរួចផុតពីមានទោសហើយ..." (បកប្រែក្រៅផ្លូវការ)។

[5] ដូចឯកសារយោងខាងលើ, ត្រង់ផ្នែកពាក់ព័ន្ធ មាត្រា ២១ ចែងថា "ទោសឧក្រិដ្ឋមាន ៣ យ៉ាង៖ ១. សម្លាប់, ២. បង្ខំឱ្យធ្វើការជាទម្ងន់អស់មួយជីវិត, ៣. បង្ខំឱ្យធ្វើការជាទម្ងន់ មានកំណត់កាល...ទោសសម្លាប់ជាទោសឧក្រិដ្ឋថ្នាក់ទី ៣ ...ទោសបង្ខំឱ្យធ្វើការជាទម្ងន់អស់មួយជីវិត ជាទោសឧក្រិដ្ឋថ្នាក់ទី ២...ទោសបង្ខំឱ្យធ្វើការជាទម្ងន់ មានកំណត់ ជាទោសឧក្រិដ្ឋថ្នាក់ទី ១"។ ត្រង់ផ្នែកពាក់ព័ន្ធ មាត្រា ៣២ ចែងថា៖ "ទោសបង្ខំឱ្យធ្វើការជាទម្ងន់អស់មួយជីវិត ត្រូវសម្រេចដាក់គុកមនុស្សដែលមានទោសនោះ អស់មួយជីវិត"។ ត្រង់ផ្នែកពាក់ព័ន្ធ មាត្រា ៣៣ ចែងថា "ទោសបង្ខំឱ្យធ្វើការជាទម្ងន់មានកំណត់ ត្រូវសម្រេចធ្វើទោសពី ៥ ឆ្នាំយ៉ាងតិច ដល់ ២០ ឆ្នាំយ៉ាងច្រើន...សម្រាប់ទោសឧក្រិដ្ឋថ្នាក់ទី ១" (បកប្រែក្រៅផ្លូវការ)។

[6] ត្រង់ផ្នែកពាក់ព័ន្ធ ច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក មាត្រា ៣៩ ចែងថា "ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា ៣ ថ្មី, មាត្រា ៤, មាត្រា ៥, មាត្រា ៦ [អំពើបំពារបំពានធ្ងន់ធ្ងរ], មាត្រា ៧ និងមាត្រា ៨ ត្រូវផ្តន្ទាទោសឧក្រិដ្ឋ ដាក់ពន្ធនាគារពី ៥ ឆ្នាំរហូតដល់មួយជីវិត"។

៤. អាជ្ញាយុកាលនៃបទល្មើសដែលនៅជាធរមានសម្រាប់អំពើបំពារបំពានធ្ងន់ធ្ងរ បានកន្លងហួសទៅហើយ ហើយមិនអាចពន្យារពេលបន្ថែមដែលមានភាពប្រតិសកម្មបានឡើយ។ ការធ្វើនេះនឹងរំលោភបំពានលើគោលការណ៍មិនប្រតិសកម្មនៃច្បាប់ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ១៩៥៦[7] និងមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[8] និងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស[9] ដែល អវតក ត្រូវតែគោរពដោយអនុលោមទៅតាមរដ្ឋធម្មនុញ្ញកម្ពុជា[10]។

៥. ប្រទេសខ្លះដែលប្រកាន់ប្រព័ន្ធច្បាប់ស៊ីវិលឡូ ដូចជាអតីតអាល្លឺម៉ង់ខាងលិច[11] និងហុងគ្រី[12] បានសម្រេចថាការចោទប្រកាន់ដោយផ្អែកតាមការពន្យារអាជ្ញាយុកាលបទល្មើស ដែលមានអនុភាពប្រតិសកម្ម គឺផ្ទុយពីរដ្ឋធម្មនុញ្ញ កាលណាអាជ្ញាយុកាលមុនបានផុតរលត់ទៅហើយ។ នៅក្នុងយុត្តាធិការផ្សេងទៀត ដូចជាប្រទេសហូឡង់ដ៍ ស្ថាប័ននីតិបញ្ញត្តិបានប្រកាសលុបចោលអាជ្ញាយុកាលនៃបទល្មើសសម្រាប់បទល្មើសធ្ងន់ធ្ងរ ប៉ុន្តែបានប្រុងប្រយ័ត្នដោយមិនអនុវត្តវិសោធនកម្ម ដែលមានអានុភាពប្រតិសកម្មចំពោះបទល្មើស ដែលផុតអាជ្ញាយុកាលឡើយ[13]។ ក្នុងពេលថ្មីៗនេះ រដ្ឋសភានៃប្រទេសជប៉ុនបានប្រកាសលុបចោលអាជ្ញាយុកាលសម្រាប់បទមនុស្សឃាដ និងបានពន្យារអាជ្ញាយុ-កាលសម្រាប់បទល្មើសមួយចំនួនផ្សេងទៀត ។ ច្បាប់ថ្មីនេះអនុវត្តចំពោះតែករណីដែលអាជ្ញាយុកាលពីមុនមិនទាន់ផុតនៅឡើយ[14]។

---

[7] *សូមមើល* ក្រមព្រហ្មទណ្ឌ ១៩៥៦ មាត្រា ៦។

[8] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៥(១)។

[9] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១១(១)។

[10] *សូមមើល* រដ្ឋធម្មនុញ្ញ មាត្រា ៣១។

[11] *សូមមើល* អត្ថបទរបស់ Martin Clausnitzer, *អាជ្ញាយុកាលចំពោះបទល្មើសមនុស្សឃាដ នៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់* 29 Int'l & COMP. L.Q. 473, 478-79 (1980) ("អត្ថបទរបស់ Clausnitzer")។

[12] *សូមមើល* អត្ថបទរបស់ RUTH A. KOK, *អាជ្ញាយុកាលនៃបទល្មើសនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (STATUTORY LIMITATIONS IN INTERNATIONAL CRIMINAL LAW)289 (2007) ("អត្ថបទរបស់ KOK")។

[13] *ដូចជើងទំព័រខាងលើ* ត្រង់២៩៩-៣០១។

[14] *សូមមើល* អត្ថបទរបស់ Shinichi Kawarada, *ជប៉ុនលុបចោលអាជ្ញាយុកាលនៃបទល្មើសមនុស្សឃាត ហើយពន្យារអាជ្ញាយុកាលបទល្មើសផ្សេងទៀត* (*Japan Abolishes Statute of Limitations on Murder, Extends Others*), ASAHI SHIMBUN, ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០។

៦. តុលាការកំពូលសហរដ្ឋអាមេរិក ដែលរដ្ឋធម្មនុញ្ញរបស់ខ្លួនហាមការអនុវត្តច្បាប់ប្រតិសកម្ម បានប្រឈមមុខនឹងបញ្ហាដូចគ្នានេះដែរក្នុងរឿងក្តី Stronger *ទល់នឹង* California[15]។ ក្នុងរឿងក្តីនោះ អ្នកដាក់ពាក្យបណ្តឹង Stogner ត្រូវបានចោទប្រកាន់ក្នុងឆ្នាំ១៩៩៨ ពីបទបំពានផ្លូវភេទលើកុមារ ដែលត្រូវបានអះអាងថាបានកើតឡើងក្នុងចន្លោះឆ្នាំ១៩៥៥ និង ១៩៧៣។ ក្នុងអំឡុងពេលដែលមានការចោទប្រកាន់ថាបទល្មើសបានកើតឡើងនោះ អាជ្ញាយុកាលនៃបទល្មើសមានរយៈពេលតែបី (០៣)ឆ្នាំតែប៉ុណ្ណោះ។ អាជ្ញាយុកាលនៃបទល្មើសថ្មីដែលត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៣ បានអនុញ្ញាតឲ្យចោទប្រកាន់នៅពេល ដែលអាជ្ញាយុកាលពីមុនបានផុតរលត់ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានធ្វើឡើងក្នុងរយៈពេលមួយ(០១)ឆ្នាំ គិតចាប់ពីពេលដែលជនរងគ្រោះបានដាក់ពាក្យបណ្តឹងទៅនគរបាល។ តុលាការបានយល់ឃើញថា ខ្លួនមិនអាចយកអាជ្ញាយុកាលនៃបទល្មើសថ្មីមកអនុវត្តចំពោះ Stronger បានទេ។ តុលាការនេះបានពន្យល់ថា បញ្ហា<u>មិនមែន</u>នៅត្រង់ថា ការបំពានផ្លូវភេទលើកុមារត្រូវបានចាត់ទុក ឬមិនចាត់ទុកជាបទល្មើសក្នុងពេលពាក់ព័ន្ធនោះទេ ប៉ុន្តែ "បញ្ហាវានៅត្រង់ថា វិសោធនកម្មត្រូវបានធ្វើឡើងបន្ទាប់ពី (មិនមែនមុនពេល) អាជ្ញាយុកាលនៃបទល្មើសដំបូងបានផុតរលត់ ដូច្នេះភាគីដូចជា Stronger "មិនត្រូវទទួលខុសត្រូវលើទណ្ឌកម្មអ្វីពីអំពើនោះឡើយ"។ ដូច្នេះ ច្បាប់ថ្មីរបស់រដ្ឋ Califonia "បានដាក់ស្លាកទម្ងន់" ទៅលើបទល្មើសដែលត្រូវបានចោទប្រកាន់ចំពោះ Stronger ឬបានធ្វើបទល្មើសនោះ "ធ្ងន់ធ្ងរជាងពីមុនពេលដែលប្រព្រឹត្តអំពើនោះ" ក្នុងវិសាលភាពមួយដែលមានន័យដែលថា "វាបង្កឲ្យមានការផ្តន្ទាទោស" ទៅលើអំពើក្នុងអតីតកាលដែល (បើគ្មានច្បាប់ថ្មីត្រូវបានអនុម័ត) មិននាំឲ្យមានការទទួលខុសត្រូវបែបនេះឡើយ"[16]។ តុលាការបានសម្រេចថា៖

> បញ្ហាទីមួយ តាមទស្សនៈរបស់តុលាការនេះ ច្បាប់ថ្មីនឹងបង្កឲ្យមានការអន្តរាយ ដែលបទប្បញ្ញត្តិស្តីពីនៃខប្បញ្ញត្តិនៃច្បាប់អប្រតិសកម្ម *Ex Post Facto* Clause ព្យាយាមជៀសវាង។ ជាយូរណាស់មកហើយ តុលាការបានចង្អុលបង្ហាញថា ខប្បញ្ញត្តិការពារសេរីភាពតាមរយៈការរារាំងកុំឲ្យរដ្ឋាភិបាលធ្វើច្បាប់ដែលមានអានុភាពប្រតិសកម្ម "*អយុត្តិធម៌និងគាបសង្កត់* ជាក់ស្តែង"។ ក្រោយមកចៅក្រម Learned Hand បានសរសេរថា ការពន្យារអាជ្ញាយុកាលបទល្មើសបន្ទាប់ពីរដ្ឋបានធានាចំពោះ "មនុស្សណាម្នាក់ដែលមនុស្សនេះបានមានសុវត្ថិភាពវិញហើយពីការតាមស្វែងរក

---

[15] *រឿងក្តី Stogner តទល់នឹង California*, 539 U.S. 607 (2003)។

[16] *ដូចជើងទំព័រខាងលើ* ត្រង់៦១៣។

របស់រដ្ឋនោះ ... ធ្វើទំនងជាអោយភាគច្រើននៃយើងទាំងអស់គ្នាយល់ថា គ្មានយុត្តិធម៌និងគ្មានសុចរិតទេ"។ ក្នុងករណីនេះ រដ្ឋាភិបាលបានសម្រេច "មិនគោរពតាមច្បាប់របស់ខ្លួនឡើយ"។ រឿងនេះបានរារាំងចុងចោទពីការទទួលបាន "ការព្រមានសមស្រប" ដែលអាចនាំឱ្យគាត់រក្សាទុកភស្តុតាងដោះបន្ទុក[17]។

៧. ភស្តុតាងទាក់ទងនឹងយោបល់រដ្ឋទាំងឡាយយល់ថាការលុបចោល ឬវិសោធនកម្មនៃអាជ្ញាយុកាលសម្រាប់បទល្មើសទាំងឡាយដែលបណ្តឹងអាជ្ញាត្រូវបានរលត់ ជាការបំពានដល់គោលការណ៍អប្រតិសកម្ម អាចរកឃើញនៅក្នុងប្រតិកម្មរបស់រដ្ឋទាំងឡាយទៅលើអនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដោយពិចារណាថា អនុសញ្ញានេះនឹងរំលោភបំពានគោលការណ៍អប្រតិសកម្ម ដោយសារអនុសញ្ញានេះមានន័យថាអាចអនុវត្តទៅលើបទល្មើសទាំងនេះ "ដោយមិនគិតពីកាលបរិច្ឆេទដែលការប្រព្រឹត្តបទល្មើសទាំងនេះឡើយ"[18]។ ដោយសារមូលហេតុនេះ អនុសញ្ញានេះមិនត្រូវបានផ្តល់សច្ចាប័នទូលំទូលាយទេ[19]។ ជាឧទាហរណ៍ ដោយសារតែមូលហេតុនេះ ប្រទេសហូឡង់មិនបានធ្វើសច្ចាប័នលើអនុសញ្ញានេះឡើយ[20] ហើយប្រទេសម៉ិកស៊ិក និងប្រទេសប៉េរូ បានធ្វើសច្ចាប័នតែបន្ទាប់ពីបានភ្ជាប់សេចក្តីប្រកាសរក្សាសិទ្ធិដែលចែងថា អនុសញ្ញានេះមិនអនុវត្តចំពោះបទល្មើសទាំងឡាយ ដែលត្រូវបានប្រព្រឹត្តមុន

---

[17] *ដូចជើងទំព័រខាងលើ* ត្រង់១១ (ការទាញសំអាងហេតុខាងក្នុងត្រូវបានលុប)។

[18] អនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាលនៃបទល្មើសចំពោះបទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ G.A. Res. 2391 (XXIII), Annex, 23 U.N. GAOR Supp. (No. 18) at 40, U.N. Doc. A/7218 (1968), មាត្រា ១។

[19] *សូមមើល* អត្ថបទរបស់ Christine Van den Wyngaert & John Dugard, *សេចក្តីអធិប្បាយ៖ ការមិនអនុវត្តអាជ្ញាយុកាលនៃបទល្មើសនៅក្នុងច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ* (*Non-Applicability of Statute of Limitations*, *in* THE ROME STATUTE OF THE INTERNATIONAL CRIMINAL COURT: A COMMENTARY) VOL. 1 874-75 (បោះពុម្ពដោយ Oxford University Press, 2002)។

[20] *សូមមើល* អត្ថបទរបស់ Alper Cinar & Sander van Niekerk, *ការអនុវត្តច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមនៅប្រទេសហូឡង់* (*Implementation of the Rome Statute in the Netherlands*) ទំព័រ ៦ *មាននៅ:* http://papers.ssrn.com/sol3/papers.cfm?abstract_id=996521 ។

00643922



អនុសញ្ញានេះចូលជាធរមានឡើយ[21]។ កម្ពុជាមិនដែលបានចុះហត្ថលេខា ឬ ផ្ដល់សច្ចាប័នលើអនុសញ្ញានេះឡើយ។

៨. ប្រទេសបារាំង ដែលប្រព័ន្ធច្បាប់ប្រទេសកម្ពុជាយកគំរូតាមនោះ បែងចែងខុសគ្នារវាងអំពើបំពារបំពានធ្ងន់ធ្ងរ ដែលមានអាជ្ញាយុកាលមួយ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមិនមានអាជ្ញាយុកាល។ ប្រទេសបារាំង បានការពារយ៉ាងមាំទាំចំពោះអាជ្ញាយុកាលនៃបទល្មើសរបស់ខ្លួនចំពោះការចោទប្រកាន់ទាំងឡាយពីបទឧក្រិដ្ឋកម្មសង្គ្រាម ដរាបណាវាមិនបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងរឿងក្ដី *Barbie* តុលាការកំពូលបានថ្លែងថា៖

> បន្ទាប់ពីការបញ្ចប់ការធ្វើសង្គ្រាម វាជាការចាំបាច់ដែលថាការកន្លងហួសនៃពេលវេលា គួរត្រូវបានអនុញ្ញាតដើម្បីអោយបំភ្លេចចោលនូវភាពឃោរឃៅ ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ទោះបីជាអំពើទាំងនោះបង្កើតបានជាការរំលោភបំពានលើច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាមក៏ដោយ ឬវាមិនមានយុត្តិកម្មតាមរយៈភាពចាំបាច់ខាងយោធានោះ ដោយហេតុថា អំពើទាំងនោះតាមលក្ខណៈធម្មជាតិរបស់វាមិនមានគុណសម្បត្តិគ្រប់គ្រាន់បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សឡើយ។ គ្មានគោលការណ៍ច្បាប់ណាដែលមានអំណាចលើច្បាប់បារាំង ដែលនឹងអនុញ្ញាតអោយឧក្រិដ្ឋកម្មសង្គ្រាម ... យកមកប្រកាសអនុវត្តដោយមិនមានអាជ្ញាយុកាលនៃបទល្មើសនោះទេ[22]។

ប្រទេសបារាំង ដូចជាប្រទេសកម្ពុជាដែរ មិនដែលក្លាយជាភាគីនៃអនុសញ្ញាស្ដីពីការមិនអនុវត្តនូវអាជ្ញាយុកាលនៃបទល្មើសទៅលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។ ដោយមានចែងយ៉ាងជាក់លាក់ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនមានអាជ្ញាយុកាលនៃបទល្មើស ហើយដោយមិនបានចែងបញ្ចូលនូវភាពជាក់លាក់នៃបទប្បញ្ញត្តិនេះទាក់ទងនឹងអំពើបំពារបំពានធ្ងន់ធ្ងរ ច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក ជាក់ស្ដែងត្រូវបានគេពង្រាងដោយយកគំរូតាមវិធីសាស្ត្ររបស់ប្រទេសបារាំងដោយបែងចែខុសពីគ្នារវាងបទឧក្រិដ្ឋទាំងពីរនេះ។

---

[21] *សូមមើល*អត្ថបទរបស់ KOK ត្រង់ទំព័រ២៩៩។

[22] *រឿងក្ដី Barbie* តុលាការកំពូល ប្រទេសបារាំង សាលដីកាចុះថ្ងៃទី ២០ ធ្នូ ១៩៨៥ JCP 1986, II, no. 20655; *Bull. Crim.* 1985, 1038-55 (បកប្រែក្រៅផ្លូវការ)។

៩. គោលការណ៍នៃការបកស្រាយតឹងរឹង តម្រូវថានៅពេលដែលច្បាប់មួយមានលក្ខណៈច្បាស់លាស់ហើយនោះ វាត្រូវយកមកអនុវត្តដូចដែលពេលព្រាងវាដែរ។ មាត្រា ៤ និង ៥ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ចែងយ៉ាងច្បាស់ព្រមគ្នាថា "ដែលគ្មានអាជ្ញាយុកាល" ។ មាត្រា ៦ មិនមានចែងដូច្នេះទេ។ ហេតុដូច្នេះ មាត្រា ៦ មានអាជ្ញាយុកាលនៃបទល្មើស ដែលជាអាជ្ញាយុកាលនៃបទល្មើសដែលអាចយកមកអនុវត្ត ទៅលើឧក្រិដ្ឋកម្មទាំងអស់ដែលបានប្រព្រឹត្តឡើងនៅប្រទេសកម្ពុជានៅអំឡុងកាលពាក់ព័ន្ធ ដោយអនុលោមទៅតាមក្រមព្រហ្មទណ្ឌ ១៩៥៦។ បើសិនជាអង្គជំនុំជម្រះសាលាដំបូង សម្រេចថា វាមានភាពមិនច្បាស់លាស់នៅក្នុងច្បាប់ ភាពមិនច្បាស់លាស់បែបនេះត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ[23]។ នេះគឺអនុលោមទៅតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដូចមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

## II. សំណូមពរ

**អាស្រ័យហេតុនេះ** ដោយយោងតាមសំអាងហេតុខាងលើ សហមេធាវីការពារក្តីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាសម្រេចថា អាជ្ញាយុកាលលើបណ្តឹងអាជ្ញាដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហាមឃាត់ការយកមាត្រា ៦ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក មកអនុវត្តនៅ អ.វ.ត.ក។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកនូវញ្ញត្តិកម្មនេះដោយក្តីគោរព។

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** | **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១

---

[23] "អំណាចក្នុងការបង្កើតបទល្មើសគឺជាស្ថិតលើដៃរបស់នីតិបញ្ញត្តិមិនមែនតុលាការឡើយ។ ភាពស្រពិចស្រពិលនៅក្នុងអត្ថន័យនៃបទបញ្ញត្តិច្បាប់ តាមរយៈការបកស្រាយតឹងរឹង គួរត្រូវបានជាប្រយោជន៍ទៅជនជាប់ចោទ" អត្ថបទរបស់ MACHTELD BOOT ក្រោមចំណងជើងថា **គ្មានបទល្មើសបើគ្មានច្បាប់ចែង និងយុត្តាធិការលើបទល្មើសនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ** (NULLUM CRIMEN SINE LEGE AND THE SUBJECT MATTER JURISDICTION OF THE INTERNATIONAL CRIMINAL COURT) ទំព័រ ១១២ (Intersentia 2002)។